# មេរៀនទី ៣: ព្រះអង្គសង្គ្រោះយាងមកដល់ហើយ

## លូកា ១:២៦- ២:៧

**គោលបំណង៖** ព្រះអង្គយាងមកដើម្បីជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប។

**ខគម្ពីរចងចាំ៖ ម៉ាថាយ១:២១** *"នាងនឹងប្រសូតបុត្រា១ ហើយអ្នកត្រូវថ្វាយព្រះនាមថា«យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះអង្គបានយាងមកដោយផ្ទាល់ មិនមកដើម្បីដាក់ទោសដល់រាស្ត្រទ្រង់ទេ ប៉ុន្តែមកដើម្បីជួយសង្គ្រោះដល់រាស្ត្ររបស់ទ្រង់វិញ ដោយព្រះបានបង្រៀន ប្រោសជំងឺ ប្រដៅដំរង់ និងធ្វើការអស្ចារ្យជាច្រើន។ តាមរយៈព្រះយេស៊ូវដែលជាព្រះមេស្ស៊ី ព្រះអង្គបានត្រៀមជាស្រេចដើម្បីជូតទឹកភ្នែកពួកគេចេញ។ មនុស្សគ្រប់គ្នាត្រូវការសេចក្តីសង្គ្រោះ ពីព្រោះមនុស្សគ្រប់គ្នាសុទ្ធតែមានបាបមិនថាកុមារ ឬមនុស្សចាស់ទេ។ សូមអធិស្ឋានសំរាប់កុមារទាំងអស់ ដែលអ្នកកំពុងបង្រៀននៅថ្ងៃនេះ ដូច្នេះហើយពួកគេអាចនឹងមកស្គាល់ព្រះមេស្ស៊ីដែរ។

**ចំរៀង៖** ១. អំណរដល់លោក ២. Joy To the World Everybody ៣. ទារកតូចអើយ ៤. ណូអែលឆ្នាំនេះ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ស្វែងរកក្រោលសត្វ និងបុត្រតូច»**

**សម្ភារៈដែលត្រូវការ៖** ក្រដាស ឬកាត ៤សន្លឹក ដោយសរសេរជាពាក្យឬដាក់ជារូបភាពក៏បាន (បើមានរូបភាព) តែបើមិនមានគ្រូត្រូវសរសេរនៅលើក្រដាសនោះដូចជា៖ ក្រដាសទី១ សរសេរពាក្យថា ផ្ទះ ក្រដាសទី២ ក្រោលសត្វ ក្រដាសទី៣ បុត្រតូចក្រដាសទី៤ ក្រោលសត្វ និងបុត្រតូច។

១. មុនចាប់ផ្តើមថ្នាក់រៀន គ្រូត្រូវយកក្រដាសឬកាតទាំង ៤សន្លឹកនោះ ទៅបិទនៅលើជញ្ជាំងនៅតាមជ្រុងទាំង ៤ ផ្សេងៗគ្នា ដោយបិតផ្កាប់មុខទៅជញ្ជាំង (កុំឲ្យសិស្សមើលឃើញ)។

២.ឲ្យកុមារទាំងអស់ឈរនៅចំកណ្តាល ដោយគ្រូត្រូវចាក់ភ្លេងឲ្យកុមាររាំជុំវិញទីធ្លានោះ ឬក៏ច្រៀងតាមបទភ្លេង រហូតនៅពេលភ្លេងឈប់កុមារត្រូវរត់ទៅកន្លែងដែលមានបិតកាត ឬក្រដាស។

៣. បន្ទាប់មកគេត្រូវបើកកាតតាមកន្លែងដែលពួកគេបានរត់ទៅ។ បើកាតណាមានរូបភាព ឬពាក្យក្រោលសត្វ និងបុត្រតូចក្រុមនោះជាអ្នកឈ្នះ។

**៤. ការណែនាំមេរៀន**

ប្រសិនបើនៅថ្ងៃនេះនាយករដ្ឋមន្ត្រីចុះមកភូមិរបស់ប្អូនតើប្អូនត្រូវរៀបចំអ្វីខ្លះដើម្បីទទួលគាត់? យើងត្រូវរៀបចំកៅអី តុ កំរាលព្រំ មានអ្នកស្វាគមន៍ ហើយនិងមានអ្នកការពារឆ្វេងស្តាំ។ តើប្អូនមានអារម្មណ៍ដូចម្តេចនៅពេលដែលមាននាយករដ្ឋមន្ត្រីមកលេងភូមិរបស់ប្អូន? តើប្អូននឹងមានអារម្មណ៍រំភើប? ខ្លាច? ឬក៏រីករាយ? ព្រះអង្គបាន

យាងមកដើម្បីជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ ដូចដែលទ្រង់បានសន្យាតាំងពីដើមដំបូងមក។ ពេលដែលព្រះមេស្ស៊ីយាងមកភ្នំទាំងឡាយនឹងឱនចុះ សមុទ្រនឹងក្រើកឡើង ដើមឈើទាំងឡាយនឹងទះដៃអបអរសាទរទ្រង់។ ប៉ុន្តែផែនដីនឹងទប់ដង្ហើមដោយស្ងប់ស្ងាត់។ តើប្អូននិងរៀបចំបែបណាសំរាប់ទទួលការយាងមករបស់ព្រះយេស៊ូវ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មានស្រីក្រមុំម្នាក់ឈ្មោះ ម៉ារាបានភ្ជាប់ពាក្យជាមួយនឹងបុរសម្នាក់ឈ្មោះយ៉ូសែប (យ៉ូសែបជាកូនចៅជំនាន់ក្រោយៗរបស់ស្តេចដាវីឌ)។ នៅព្រឹកមួយស្រីក្រមុំម្នាក់នោះកំពុងធ្វើការដូចសព្វដង ស្រាប់តែមានទេវតាពេញដោយពន្លឺចេញមកជួបនាង ទេវតានោះមានព្រះនាមថា កាព្រីយ៉ែលជាអ្នកនាំសារពិសេសមកពីស្ថានសួគ៌បានឈរនៅចំពោះនាង **លូកា១:៣០-៣២** "តែទេវតានិយាយថា កុំខ្លាចអីម៉ារាអើយ ដ្បិតព្រះបានប្រោសមេត្តាដល់នាងហើយ មើលនាងនឹងមានគភ៌ប្រសូតបានបុត្រា១ ដែលនាងត្រូវថ្វាយព្រះនាមថា «យេស៊ូវ» បុត្រនោះនឹងបានជាធំឧត្តម ហើយគេនឹងហៅទ្រង់ថា ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត" ទេវតាកាព្រីយ៉ែលបាននិយាយពីការយាងមករបស់ព្រះអង្គសង្គ្រោះគឺព្រះមេស្ស៊ី!

**លូកា ១:៣៤-៣៥** តែម៉ារាសួរទេវតាថា "ខ្ញុំមិនស្គាល់ប្រុសណាផង ដូច្នេះ តើធ្វើដូចម្តេចនឹងឲ្យការនេះសំរេចបាន ទេវតាក៏ឆ្លើយថា ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាង ហើយព្រះចេស្តានៃព្រះដ៏ខ្ពស់បំផុតនឹងមកគ្របបាំងនាងដោយស្រមោល ហេតុដូច្នេះបុត្របរិសុទ្ធដែលនឹងប្រសូតមកនោះ ត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ" នាងក៏និយាយថា "សូមឲ្យបានសំរេចដូចពាក្យលោកចុះ។" ពិតប្រាកដណាស់ដូចជាពាក្យទេវតាបានប្រាប់មែន ក្រោយនោះមកនាងម៉ារាជិតគ្រប់ខែសំរាលកូន ហើយឥឡូវនេះនាងម៉ារានិងយ៉ូសែបកំពុងធ្វើដំណើរទៅបេថ្លេហិមជាស្រុកកំណើតរបស់ស្តេចដាវីឌ។ នៅពេលដែលទៅដល់បេថ្លេហិមនាងក៏ចាប់ផ្តើមឈឺពោះ ហើយគ្រប់បន្ទប់នៃផ្ទះសំណាក់ពេញទាំងអស់ ក៏គ្មានកន្លែងណាដែលទំនេរសោះ។

ម្ចាស់ផ្ទះសំណាក់បានប្រាប់ម៉ារា និងយ៉ូសែបឲ្យទៅរកកន្លែងស្នាក់នៅផ្សេងទៀត តើឲ្យពួកយើងទៅស្នាក់នៅកន្លែងណា? នៅតែបន្តិចទៀតម៉ារានឹងសំរាលកូនហើយ។ ពួកគេមិនអាចរកកន្លែងស្នាក់នៅបានសោះ លើកលែងតែក្រោលសត្វមួយដែលទ្រុឌទ្រោមទៅហើយ ដូច្នេះពួកគេក៏បានសំរាលបុត្រតូចនៅកន្លែងនោះ ព្រះមេស្ស៊ីជាព្រះអង្គសង្គ្រោះនៃពិភពលោកបានប្រសូត្រនៅក្នុងក្រោលសត្វ ជាកន្លែងដែលហ្វូងគោ ហ្វូងលា ហើយហ្វូងសេះកំពុងនៅ។ នៅក្នុងក្រោលសត្វនាយប់ដ៏សែនស្ងាត់ជ្រងំ នាងម៉ារានិងយ៉ូសែបបានរុំទារកតូចនឹងសំពត់ដើម្បីជួយឲ្យកក់ក្តៅដោយប្រើស្នូកដាក់ចំណីសត្វធ្វើជាគ្រែឲ្យបុត្រតូចផ្ទំនៅក្នុងស្នូកនោះ។ ម៉ារានិងយ៉ូសែបបានដាក់ឈ្មោះទ្រង់ដូចជាទេវតាបានប្រាប់ (ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប) ព្រោះនេះគឺជាការពិតណាស់ដ្បិតទ្រង់បានយាងមកពិតមែន។ រឿងនេះបានសំរេចដូចជាសេចក្តីទំនាយបានទាយទុក និងតាមការសន្យារបស់ព្រះ ដែលទ្រង់បានចាត់ព្រះយេស៊ូវមករកយើង!

## ៦. សំនួរពិភាក្សា

១. តើទេវតាបានជួបនរណា? *ម៉ារា*

២. តើទេវតាដែលម៉ារាបានជួបនោះមានឈ្មោះអ្វី? *កាព្រីយ៉ែល*

៣. តើបុត្រតូចបានប្រសូតនៅកន្លែងណា?*ក្រោលសត្វ*
៤. តើបុត្រតូចនោះមានព្រះនាមអ្វី?*យេស៊ូវ*
៥. តើបុត្រតូចនោះយាងមកផែនដីដើម្បីអ្វី?*ជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប*
៦. តើប្អូនៗគិតថាព្រះយេស៊ូវយាងមកសង្គ្រោះមនុស្សប្រភេទណាខ្លះ? *មនុស្សគ្រប់គ្នា*

## ៧. ល្បែងកំសាន្ត «បកសំបក»

**សម្ភារៈដែលត្រូវការៈ** ក្រដាស A4 ចំនួន ១៥ សន្លឹក
១. គ្រូត្រូវសរសេរពាក្យដាក់នៅក្នុងក្រដាសនោះជាពាក្យផ្សេងៗគ្នាដូចជា សើច យំ រាំ ច្រៀង ធ្វើកាយវិការសត្វស្វា សំលេងសត្វទា ដើរបង្ហាញម៉ូត។ល។ ក្នុងចំណោមក្រដាសទាំងនោះត្រូវមានរង្វាន់២ ឬ៣សន្លឹក។
២. បន្ទាប់មកគ្រូយកក្រដាសដែលសរសេររួច មកផ្ទួលចូលគ្នាឲ្យក្លាយជាបាល់ ដែលយើងអាចបកបានជាស្រទាប់ៗ។
៣. ឲ្យកុមារអង្គុយជុំវិញជារង្វង់មូល។
៤. ហើយឲ្យបាល់នោះទៅកុមារណាម្នាក់។
៥. ឲ្យកុមារហុចបាល់នោះតៗគ្នា ទន្ទឹមនឹងនោះគ្រូត្រូវចាក់ភ្លេងផងដែរ នៅពេលបទភ្លេងឈប់ហើយបាល់នៅលើអ្នកណាអ្នកនោះត្រូវបកបាល់មួយស្រទាប់ បើបើកត្រូវចំពាក្យអ្វីកុមារត្រូវធ្វើត្រាប់តាមពាក្យនៅក្នុងក្រដាសនោះ
៦. យើងបន្តលេងល្បែងនេះរហូតដល់បកស្រទាប់ក្រដាសនោះអស់។

## ៨. ខគម្ពីរចងចាំ ម៉ាថាយ ១:២១

## ៩. ហត្ថកម្ម «ក្រោលសត្វ»



**ជំរើសទី១ៈ**បង្រៀនឲ្យកុមារចេះធ្វើក្រោលសត្វ(ដាក់បុត្រតូច និងឈ្មោះអេម៉ាញូអែល) ក្រោលសត្វនេះធ្វើ ពីឈើការ៉េមដាក់ដំបូល។
**ជំរើសទី២ៈ** ផាត់ពណ៌សូមបោះពុម្ពរូបភាពឲ្យកុមារផាត់ពណ៌នៅទំព័រខាងក្រោម។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះអង្គសង្គ្រោះយាងមកដល់ហើយ



**ម៉ាថាយ ១:២១** *“នាងនឹងប្រសូតបុត្រា១ ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ»*
*ព្រោះបុត្រនោះនឹង ជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប។”*